**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤៥០៧ អយក.ហរ

ថ្ងៃ ពុធ ៦ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

**សូមជម្រាបជូន**
**ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គាធិការ សាកលវិទ្យាធិការ**
**នាយកវិទ្យាស្ថាន លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង**

**កម្មវត្ថុ ៖** ការដាក់ឱ្យអនុវត្តជាផ្លូវការ "**ការបើកប្រាក់បៀវត្ស និងប្រាក់បេសកកម្មក្នុងប្រទេសតាមប្រព័ន្ធធនាគារ អេស៊ីលីដា ភីអិលស៊ី**" ជូនមន្ត្រីអប់រំក្រោមឱវាទទីស្តីការក្រសួង។

**យោង ៖**
- សារាចរណែនាំលេខ០១២ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការទូទាត់ត្រង់ចូលគណនីប្រាក់បៀវត្សមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ២០២០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា
- លិខិតលេខ២៣០៨ អយក.ហរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ស្តីពីការជូនដំណឹងដល់ថ្នាក់ដឹកនាំ និងមន្ត្រីអប់រំ បើកគណនីចរន្តជាប្រាក់រៀលជាមួយធនាគារអេស៊ីលីដា ភីអិលស៊ី។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ** ជាប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង ជ្រាបថា៖ ការបើកប្រាក់បៀវត្ស និងប្រាក់បេសកកម្មក្នុងប្រទេសតាមប្រព័ន្ធធនាគារអេស៊ីលីដា ភីអិលស៊ី នឹងត្រូវដាក់ឲ្យអនុវត្តជាបន្តបន្ទាប់ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២០ តទៅ។ ដូច្នេះ ដើម្បីឲ្យយន្តការបើកផ្តល់នេះ អាចអនុវត្តទៅបានប្រកបដោយ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមសារាចរណែនាំលេខ០១២ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ និងផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសូមស្នើ **ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ប្រធានអង្គភាពថវិកា និងមន្ត្រីអប់រំ** ក្រោមឱវាទទីស្តីការក្រសួង អនុវត្តតាមការណែនាំដូចខាងក្រោម៖

១. ថ្នាក់ដឹកនាំ និងមន្ត្រីអប់រំក្រោមឱវាទទីស្តីការក្រសួង ត្រូវអនុវត្តការបើកប្រាក់បៀវត្ស តាមប្រព័ន្ធធនាគារអេស៊ីលីដា ភីអិលស៊ី **ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២០** តទៅ។ នាយកដ្ឋានបុគ្គលិក ត្រូវទទួលបន្ទុក និងអនុវត្តឲ្យមានប្រសិទ្ធភាព។

២. ថ្នាក់ដឹកនាំ និងមន្ត្រីអប់រំក្រោមឱវាទទីស្តីការក្រសួង ត្រូវអនុវត្តការបើកប្រាក់បេសកកម្មក្នុងប្រទេសតាមប្រព័ន្ធធនាគារអេស៊ីលីដា ភីអិលស៊ី **ចាប់ពីខែមករា ឆ្នាំ២០២១** តទៅ។ នាយកដ្ឋានហិរញ្ញវត្ថុ និងអង្គភាពថវិកា ត្រូវទទួលបន្ទុក និងអនុវត្តឲ្យមានប្រសិទ្ធភាព។


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

៣. **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានអង្គភាពនីមួយៗ ត្រូវពិនិត្យឲ្យបានល្អិតល្អន់ និងធានាថា មន្ត្រីក្រោមឱវាទដឹកនាំរបស់ខ្លួនបានបើកគណនីចរន្តជាប្រាក់រៀលចំនួនមួយជាមួយធនាគារអេស៊ីលីដា រួចរាល់ជាស្ថាពរ។ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រី ដែលបំពេញបេសកកម្ម ឬសិក្សានៅក្រៅប្រទេស ដែលពុំអាចបើកគណនីបាន ត្រូវរក្សាការបើកផ្តល់ប្រាក់បៀវត្សតាមធនាគារឯកទេសរឹងដដែល រហូតដល់សាមីជនវិលត្រឡប់មកប្រទេសកម្ពុជាវិញ ទើបតម្រូវឲ្យទៅស្នើសុំបើកគណនីចរន្តជាប្រាក់រៀលជាមួយធនាគារអេស៊ីលីដា ភីអិលស៊ី។ ជាមួយគ្នានេះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានអង្គភាពនីមួយៗ ត្រូវរៀបចំបញ្ជីឈ្មោះមន្ត្រីដែលបានបើកគណនីរួចរាល់ហើយ និងមន្ត្រីដែលបំពេញបេសកកម្ម ឬសិក្សានៅក្រៅប្រទេស តាមទម្រង់០១ និងទម្រង់០២ ភ្ជាប់មកជាមួយ រួចបញ្ជូនមក លោក **គង់ ដារ៉ា** (០៧៨ ៦១៨ ៨៦១) អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក ក្រសួងអប់រំ យុវជន និងកីឡា យ៉ាងយូរត្រឹម **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០**។

៤. **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានអង្គភាពថវិកានីមួយៗ ត្រូវពិនិត្យឡើងវិញ និងធានាថា បានបើកគណនីចរន្តជាប្រាក់រៀល សម្រាប់អង្គភាពថវិការួចរាល់ និងត្រឹមត្រូវ ដើម្បីប្រតិបត្តិការថវិកាជូទេយ្យបុរេប្រទាន ដោយប្រធានអង្គភាពថវិកាជាម្ចាស់គណនី។ បន្ទាប់មក ត្រូវថតចម្លងគណនីដែលបានបើករួចរាល់នេះ បញ្ជូនមក លោក **ស្រ៊ន ម៉េងសុង** (០៧៧ ៦៦ ៧២ ៤២) មន្ត្រីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យ៉ាងយូរត្រឹម**ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០**។

ចំពោះចម្ងល់ពាក់ព័ន្ធនឹងការបើកគណនីជាមួយធនាគារអេស៊ីលីដា ភីអិលស៊ី សូមធ្វើការទំនាក់ទំនងទៅមន្ត្រីជំនាញរបស់ធនាគារអេស៊ីលីដា លោកស្រី **នង សុគន្ធារ៉ា** លេខទូរស័ព្ទ ០១៥ ៧០០ ០៧៩ និង លោកស្រី **ឈិត សុគន្ធា** លេខទូរស័ព្ទ ០១០ ៣០០ ០៣៩ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបនិងអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- លេខាធិការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
  "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់សាកលវិទ្យាល័យ និងវិទ្យាស្ថាន
- គ្រប់អង្គភាពថវិកា
  "ដើម្បីសហការ និងអនុវត្ត"
- កាលប្បវត្តិ ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ០១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អង្គភាព...................................

# បញ្ជីរាយនាមមន្ត្រីរាជការបើកគណនីជាមួយធនាគារអេស៊ីលីដា ភីអិលស៊ី

| ល.រ | អត្តលេខ | លេខគណនីអេស៊ីលីដា | ឈ្មោះជាអក្សរខ្មែរ | ឈ្មោះជាអក្សរឡាតាំង | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខងារ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

បញ្ចប់ត្រឹមលេខរៀងទី...............សរុបចំនួន......................នាក់ ស្រីចំនួន.........................នាក់

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**បានឃើញ និងឯកភាព**
**ប្រធានអង្គភាព**

**រៀបចំដោយ**

គំរូទី ០២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អង្គភាព.....................................

# បញ្ជីរាយនាមមន្ត្រីរាជការសិក្សា និងបំពេញបេសកកម្មនៅក្រៅប្រទេស
# ដែលត្រូវស្នើសុំការបើកប្រាក់បៀវត្ស និងប្រាក់បេសកកម្មតាមធនាគារឯកទេសវីង

| ល.រ | អត្តលេខ | លេខគណនីវីង | ឈ្មោះជាអក្សរខ្មែរ | ឈ្មោះជាអក្សរឡាតាំង | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខងារ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

បញ្ឈប់ត្រឹមលេខរៀងទី...............សរុបចំនួន......................នាក់ ស្រីចំនួន.........................នាក់

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

បានឃើញ និងឯកភាព
ប្រធានអង្គភាព

រៀបចំដោយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០១២ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០១៤

## សារាចរណែនាំ
## ស្តីពី
## ការទូទាត់ត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីរាជការ

អនុវត្តតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និងផ្អែកលើបទពិសោធន៍ដ៏ល្អនិងប្រសិទ្ធភាពខ្ពស់ក្នុងការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ នៅទូទាំងប្រទេសក្នុងរយៈកាលកន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំឱ្យក្រសួង ស្ថាប័ន មន្ទីរជំនាញ អាជ្ញាធរ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធទាំងអស់ អនុវត្តការទូទាត់ត្រង់ចំពោះទឹកប្រាក់គ្រប់ប្រភេទដែលត្រូវបើកផ្តល់ ឬទូទាត់ជូនមន្ត្រីរាជការរបស់ខ្លួនដែលមានដូចជា៖ បុព្វលាភ លាភការ ប្រាក់បំណាច់ ប្រាក់បេសកកម្ម ប្រាក់សង្គមកិច្ច ប្រាក់ឧបត្ថម្ភ ប្រាក់ម៉ោងបន្ថែម ប្រាក់បំះប៉ូវនានានិងអត្ថប្រយោជន៍បន្ថែម និងប្រាក់ឧបត្ថម្ភផ្សេងទៀត ... ។ល។ ដោយធ្វើការបង្វែរត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីរាជការផ្ទាល់តែម្តង។

គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ អាជ្ញាធរ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវសហការអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ អាជ្ញាធរ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធទាំងអស់ "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ២៣០៤ អយក.ហវ

ថ្ងៃសុក្រ ១៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០

**សូមជម្រាបជូន**
**ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គាធិការ សាកលវិទ្យាធិការ**
**នាយកវិទ្យាស្ថាន លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង**

**កម្មវត្ថុ** ៖ សំណើសុំកិច្ចសហការឱ្យធនាគារអេស៊ីលីដា ភីអិលស៊ី(ACLEDA Bank PLC) ចុះរៀបចំបំពេញបែបបទបើកគណនីចរន្តជាប្រាក់រៀលសម្រាប់ការទូទាត់ត្រង់ ដើម្បីអនុវត្តការបើកប្រាក់បៀវត្ស និងប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ ជូនមន្ត្រីអប់រំ។

**យោង** ៖- សារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការទូទាត់ត្រង់ចូលគណនីប្រាក់បៀវត្សមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ២០២០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា
- លិខិតលេខ ២៦៦៤ សហវ. អរតន ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា៖ យោងតាមបទពិសោធន៍ដ៏ល្អក្នុងការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ និងដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ចំណូល ចំណាយ លើការអនុវត្តថវិកាកម្មវិធី ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងអប់រំ យុវជន និងកីឡា នឹងអនុវត្តការបើកផ្តល់ប្រាក់បេសកកម្មក្នុងប្រទេស ដោយបង្វែរត្រង់ចូលគណនីប្រាក់បៀវត្សមន្ត្រីរាជការផ្ទាល់តែម្តង។ ក្នុងន័យនេះ ក្រសួងបានជ្រើសរើស **ធនាគារអេស៊ីលីដា ភីអិលស៊ី** ជាដៃគូអនុវត្តចំណាយថវិកាតាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ទូទាត់ត្រង់លើការបើកផ្តល់ទាំងប្រាក់បៀវត្ស និងប្រាក់បេសកកម្មក្នុងប្រទេសចាប់ពីឆ្នាំ២០២០ នេះតទៅ។ ដូច្នេះ ដើម្បីឱ្យនីតិវិធីបើកផ្តល់នេះ អនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ខ្ញុំសូមស្នើ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** អនុវត្តតាមការណែនាំដូចខាងក្រោម៖

១. អនុញ្ញាត និងសហការឱ្យធនាគារអេស៊ីលីដា ភីអិលស៊ី ចុះរៀបចំបំពេញបែបបទបើកគណនីចរន្តជាប្រាក់រៀលជូនមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់តាមកាលវិភាគដែលភ្ជាប់មកជាមួយ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

២. សម្រាប់អង្គភាពថវិកានីមួយៗ ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន០១ (មួយ)សម្រាប់ប្រតិបត្តិការថវិការជ្ជទេយ្យបុរេប្រទាន ហើយប្រធានអង្គភាពថវិកាជាម្ចាស់គណនី។

ក្នុងករណីមានបញ្ហា ឬព័ត៌មានបន្ថែមពាក់ព័ន្ធការបើកគណនីខាងលើ សូមទំនាក់ទំនងជាមួយ លោក **ស្រ៊ន ម៉េងសុង** មន្ត្រីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃលេខាធិការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំក្រសួងអប់រំ យុវជន និងកីឡា តាមរយៈទូរស័ព្ទលេខ ០៧៧ ៦៦ ៧២ ៤២។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាប និងចាត់ចែង អនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយការទទួលខុសត្រូវខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- លេខាធិការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
  "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់សាកលវិទ្យាល័យ និងវិទ្យាស្ថាន
- គ្រប់អង្គភាពថវិកា
  "ដើម្បីសហការ និងអនុវត្ត"
- កាលប្បវត្តិ ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ